**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៥១/៣០/២០១៣ ករធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣

**ជម្រាបមក**

**លោក សេំ ស៊ូ**

ទីលំនៅក្រុមប្អូន ភូមិ១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

**កម្មវត្ថុ :** សំណើសុំប្តឹងបដិសេធសេចក្តីសម្រេចលេខ ៧៩១/១៣ គ.ជ.ប ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប ។

**យោង** : - ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ

- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥
- ពាក្យបណ្តឹងរបស់លោក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣
- លិខិតលេខ ៧៩១/១៣ គ.ជ.ប ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកថា ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលពាក្យបណ្តឹងរបស់លោក និងបានដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ ពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣ រួចហើយ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា លិខិតលេខ ៧៩១/១៣ គ.ជ.ប ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ។

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh